# ខ្លឹមសារសង្ខេបនៃការសិក្សាស្រាវជ្រាវរបស់អង្គការនារីដើម្បីសន្តិភាព

## រក្សាភាពសុខដុមរមនា ឬ រារាំងយុត្តិធម៌?

ខែតុលា ឆ្នាំ២០២០



## អ្វីដែលអ្នកគួរដឹង...

ក្នុងចំណោមស្ត្រីជាច្រើនដែលប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារនិងដោយដៃគូស្និទ្ធស្នាល មានតិចតួចណាស់ដែលស្វែងរកជំនួយពីខាងក្រៅ។ ជាធម្មតា ស្ត្រីអ្នកដែលស្វែងរកជំនួយទាំងនោះ ពុំបានទទួលសេវាឆ្លើយតបប្រកបដោយការយល់ដឹងយេនឌ័រនោះទេ។ ជារឿយៗ ពួកគេឆ្លងកាត់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(ឬ ហៅថា ADR) ជាពិសេសគឺ ការផ្សះផ្សា ដែលមានគោលបំណងសំខាន់គឺជម្រុញអោយភាគីបន្តរួមរស់រក្សាជីវភាពគ្រួសារជាមួយគ្នា។ ទម្រង់នៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ(ADR)តាមបែបការផ្សះផ្សាបែបនេះ មិនបានបម្រើផលប្រយោជន៍និងការការពារសិទ្ធិស្ត្រីរងគ្រោះឡើយ។

### តើការសិក្សាស្រាវជ្រាវនេះនិយាយអំពីអ្វី?

ការសិក្សាស្រាវជ្រាវនេះបង្ហាញពីបទពិសោធន៍របស់ស្ត្រីអ្នកទទួលសេវា និង ទស្សនៈយល់ឃើញរបស់អ្នកផ្តល់សេវា ព្រមទាំងភាគីស្ថាប័នពាក់ព័ន្ធនានា ជុំវិញការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងដោយដៃគូស្និទ្ធស្នាល។ វាផ្តែកទៅលើ បទពិសោធន៍នៃការធ្វើការនៅមូលដ្ឋានជាច្រើនឆ្នាំរបស់អ្នកអនុវត្តផ្ទាល់ ដែលបានអង្កេតឃើញមានបញ្ហាជាច្រើនក្នុងការអនុវត្តដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅមូលដ្ឋានក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងដោយដៃគូស្និទ្ធស្នាល។ ការសិក្សាស្រាវជ្រាវនេះ ក៏ផ្តល់ជាអនុសាសន៍មួយចំនួនដើម្បីចូល រួមចំណែក ក្នុងការកែលម្អវផ្នែកគោលនយោបាយ និងដោះស្រាយ បញ្ហាប្រឈមនានាក្នុងការអនុវត្តនិងកំណត់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋានឲ្យបានល្អប្រសើរជាងមុនដោយផ្តោតលើការគោរពនិងការពារជនរងគ្រោះជាសំខាន់។

### តើការសិក្សាស្រាវជ្រាវនេះត្រូវបានអនុវត្តយ៉ាងដូចម្តេច?

បន្ទាប់ពីការសិក្សាពិនិត្យឯកសារដែលមានស្រាប់ឯកសារច្បាប់ និងឯកសារគោលនយោបាយពាក់ព័ន្ធនានា អ្នកស្រាវជ្រាវបានធ្វើការស្ទង់មតិកិច្ចសម្ភាសន៍និងកិច្ចពិភាក្សាជាក្រុមជាមួយអ្នកចូលរួមសរុប ១៦៧នាក់ មកពី ៤ ខេត្តក្រុង នៃព្រះរាជាណាចក្រកម្ពុជា។ អ្នកចូលរួមទាំងអស់សុទ្ធសឹងតែមានបទពិសោធន៍ ឬ ពាក់ព័ន្ធ នឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន ទាក់ទងនឹងករណីហិង្សាក្នុងគ្រួសារ និងដោយដៃគូរស្និទ្ធស្នាល។ អ្នកស្រាវជ្រាវបានពិនិត្យមើលទិន្នន័យដែលប្រមូលបាន និង ចាត់ថ្នាក់វិភាគទិន្នន័យទៅតាមប្រធានបទ និងជាក្រុមផ្សេងៗនៃអ្នកចូលរួម (រួមមាន ស្ត្រីរងគ្រោះ អាជ្ញាធរមូលដ្ឋាន មន្ត្រីប៉ូលីស ។ល។) ទិន្នន័យ ត្រូវបានវិភាគជាលើកទី២ ហើយកំណត់សម្គាល់ក្រោមប្រធានបទនីមួយៗ មុនពេលធ្វើការវិភាគសន្និដ្ឋាននិងសរសេរចូលក្នុងរបាយការណ៍ស្រាវជ្រាវ។

## តើយើងបានរកឃើញអ្វីខ្លះ?

អំពើហិង្សាប្រឆាំងស្ត្រីមានលក្ខណៈស្មុគស្មាញ ហើយក៏អាចរួមបញ្ចូលនូវទម្រង់នៃការរំលោភបំពានផ្លូវចិត្ត និងសេដ្ឋកិច្ចផងដែរ។ ស្ត្រីជាច្រើនមានអារម្មណ៍ថា ជាប់ផុងដកខ្លួនមិនរួចពីអំពើរំលោភបំពាន ដែលនេះបញ្ជាក់ពីវិសមភាពនៃអំណាចមុនពេលចូលក្នុង ដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ គ្រឿងស្រវឹងជាកត្តាចម្បងមួយក្នុងការបង្កអោយមានអំពើហិង្សា ហើយស្ត្រីជាច្រើនជឿថា វប្បធម៌ស្តីបន្ទោសជនរងគ្រោះនិងការម៉ាក់ងាយ ជាមូលហេតុដែលនៅតែធ្វើអោយស្ត្រីបន្តគិតថា ខ្លួនគួរទទួលខុសត្រូវចំពោះអំពើហិង្សា សូម្បីតែក្នុងករណីដែលពួកគេត្រូវបានអ្នកដទៃរំលោភបំពានក៏ដោយ។

ពាក្យពេចន៍បច្ចេកទេសនៃទម្រង់វិធីសាស្ត្រនានា នៃយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដូចជាការសម្រុះសម្រួល (ឬហៅថា សន្ធានកម្ម)ការផ្សះផ្សា និងអាជ្ញាកណ្តាល (ឬហៅថា មជ្ឈត្តកម្ម) ជាដើម ត្រូវបានប្រើប្រាស់ខុសបច្ចេកទេសលាយឡំគ្នា ទាំងក្នុងឯកសារសិក្សា និង ឯកសារគោលនយោបាយផងដែរ។ ការស្រាវជ្រាវនេះ រកឃើញថា ក្នុងការអនុវត្តការសម្រុះសម្រួល ក្រៅប្រព័ន្ធតុលាការជាក់ស្តែង គឺយកវិធីសាស្ត្រផ្សះផ្សា មកប្រើប្រាស់ជាជាងការសម្រុះសម្រួលតាមបច្ចេកទេសត្រឹមត្រូវ។ ស្ត្រីភាគច្រើនដែលធ្លាប់ទទួលសេវា ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះដែលមានលក្ខណៈជាការផ្សះផ្សា ក្នុងករណីហិង្សាក្នុងគ្រួសារឬដោយដៃគូស្និទ្ធស្នាលមានបទពិសោធន៍អវិជ្ជមាន។ បញ្ហាទាំងនេះ កើតឡើងដោយសារកត្តាសំខាន់ៗដូចជា ការបដិសេធ មិនបញ្ជូនករណីបន្តទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អំណាចមានព្រាបជាងរបស់ជនមុខសញ្ញានៅក្នុងសហគមន៍ ការបន្តដំណើរការដោះស្រាយវិវាទក្រៅប្រព័ន្ធទោះករណីនោះធ្លាប់បរាជ័យម្តងហើយ ម្តងទៀតក៏ដោយ និង បញ្ហាប្រឈមក្នុងការទទួលបានការលែងលះ ក្នុងការអនុវត្តជាក់ស្តែង។ ស្ត្រីភាគច្រើន (៧៨ភាគរយក្នុងការស្រាវជ្រាវនេះ) មានចំណេះដឹងតិចតួច ឬ មិនមានទាល់តែសោះ អំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានការគាំពារផ្នែកច្បាប់ដែលមានសម្រាប់ពួកគេ ក្នុងស្ថានភាពរំលោភបំពាន ចំណែកឯតួនាទី និង ដែនសមត្ថកិច្ចរបស់ប៉ូលីសក្នុងការអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅតែមិនមានភាពច្បាស់លាស់និងនៅតែជាបញ្ហាចោទ។ សម្រាប់អ្នកផ្តល់សេវា ដែលធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងករណីអំពើហិង្សក្នុងគ្រួសារនៅមូលដ្ឋាន ប្រឈមនឹងបញ្ហា ជាក់លាក់មួយចំនួនក្នុងការអនុវត្តជាក់ស្តែង។ អ្នកផ្តល់សេវាភាគច្រើន មិនមានចំណេះដឹង ឬ មិនបានទទួលការបណ្តុះបណ្តាល អំពីវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រឹមត្រូវ ឬចំណេះដឹងគតិយុត្តិពាក់ព័ន្ធ ហើយជារឿយៗ បង្វែការសម្រេចចិត្ត របស់ភាគីប្តីប្រពន្ធមិនឲ្យបន្តនីតិវិធីទៅតុលាការ។ ពេលខ្លះការប្រជុំដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន ត្រូវបានពន្យាពេល ហើយទីតាំងបន្ទប់ដោះស្រាយវិវាទមានការខ្វះខាត និងមិនមានលក្ខណៈអំណោយផល ដែលបណ្តាលឲ្យខ្វះការរក្សាការសម្ងាត់ និង ខ្វះការយកចិត្តទុកដាក់លើការយល់ដឹងពីយេនឌ័រអំឡុងពេលអនុវត្តដំណើរការប្រជុំ។ ការប្រជុំដោះស្រាយនេះទៀតសោត តែងតែទោរទន់ទៅរកការផ្សះផ្សាជាជាងការសម្រុះសម្រួលតាមបច្ចេកទេស ដែលអាចធ្វើឲ្យប៉ះពាល់ ដល់សិទ្ធិរបស់ជនរងគ្រោះដោយអំពើហិង្សា។ ជាទូទៅកិច្ចព្រមព្រៀង ដែលធ្វើឡើងនៅចុងបញ្ចប់នៃ ADR ត្រូវបានគេចាត់ទុកថា ជាលិខិតូបករណ៍មានប្រយោជន៍ ប៉ុន្តែ វាមិនត្រូវបានចងកាតព្វកិច្ច ឬ មិនត្រូវបានអនុវត្តឲ្យមានប្រសិទ្ធភាពនោះទេ។ បញ្ហាប្រឈមមួយទៀតគឺ ការឲ្យនិយមន័យ ទៅលើភាពជោគជ័យក្នុងការដោះស្រាយវិវាទមូលដ្ឋាន ដែលផ្អែកទៅលើថាតើភាគីវិវាទ(ប្តីប្រពន្ធ) សម្រេចបន្តរួមរស់ជាមួយគ្នាដែរឬទេ ហើយដែលចំនុចនេះគឺជាបញ្ហា ហើយអាចរារាំងដល់ការទទួលបានយុត្តិធម៌ របស់ស្ត្រីថែមទៀតផង។ ភាពមិនស៊ីសង្វាក់គ្នា ក្នុងការបញ្ជូនករណីទៅអាជ្ញាធរពាក់ព័ន្ធ និង ជំនឿគ្មានមូលដ្ឋានដែលថាជនមុខសញ្ញាអាចត្រូវដោះលែងវិញ ប្រសិនបើជនរងគ្រោះទម្លាក់បទចោទ បានក្លាយជាបញ្ហាប្រឈមសម្រាប់ការអនុវត្តរឹតបន្តឹងច្បាប់។ ថ្វីបើមានបញ្ហាប្រឈមជាច្រើននៅក្នុងការអនុវត្តក៏ដោយ ការសិក្សាស្រាវជ្រាវនេះរកឃើញថា អ្នកផ្តល់សេវាមានឆន្ទៈ ក្នុងការចូលរួមចំណែកក្នុងការដោះស្រាយ ហើយភាពមិនច្បាស់លាស់នៃនីតិវិធីមិនបានឆ្លុះបញ្ចាំងពីចេតនាអវិជ្ជមានរបស់អ្នកផ្តល់សេវានោះទេ។

## តើនរណាគេជាអ្នកដឹកនាំការស្រាវជ្រាវនេះ?

គំនិតផ្តួចផ្តើមក្នុងការសិក្សាស្រាវជ្រាវមួយនេះបានត្រូវដឹកនាំដោយ អ្នកស្រី គ្រី ស៊ុយហៀង នៃអង្គការនារីដើម្បីសន្តិភាព លោក មាស សារ៉ាត នៃមជ្ឈមណ្ឌលកម្ពុជាដើម្បីការសម្រុះ សម្រួល ដោយមានការសហការជាមួយ Kate Seewald នៃអង្គការក្លាហាន និង លោក សុខលាំង។

## តើយើងអាចប្រើប្រាស់ការស្រាវជ្រាវនេះយ៉ាងដូចម្តេច?

ការសិក្សាស្រាវជ្រាវនេះ អាចចូលរួមចំណែកក្នុងការធ្វើអោយប្រសើរ ឡើងនូវគោលនយោបាយនិងការអនុវត្តជាក់ស្តែង។ នៅកម្រិតថ្នាក់ជាតិ វាមានសារសំខាន់ណាស់ក្នុងការបង្កើតគោលការណ៍ណែនាំ សម្រាប់ការសម្រុះសម្រួលប្រកបដោយការយល់ដឹងពីយេនឌ័ រនិងការបណ្តុះបណ្តាលដល់មន្ត្រីផ្តល់សេវាពាក់ព័ន្ធដែលធ្វើការ លើករណីហិង្សាក្នុងគ្រួសារ និងដោយដៃគូស្និទ្ធស្នាល។ ការសម្រុះសម្រួលមិនត្រូវប្រើប្រាស់ក្នុងបទល្មើសមជ្ឈិមនោះទេ ហើយត្រូវចាត់វិធានការអោយបានម៉ត់ចត់ដើម្បីធានាសុវត្ថិភាព និងសន្តិសុខដល់ស្ត្រីរងគ្រោះ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាកាមិនត្រូវចាត់ទុកថាជា យន្តការជំនួសការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។ គោលការណ៍ណែនាំដែលមានប្រសិទ្ធិភាពជាងមុន និងមានការយល់ដឹងយេនឌ័រ គឺចាំបាច់ត្រូវធ្វើឡើង ក្នុងករណីស្ត្រីដែលស្វែងរកការផ្តាច់ចំណងអាពាហ៍ពិពាហ៍ដែលមិនមានអេតាស៊ីវិល និងក្នុងនីតិវិធីក្នុងការទទួលបានដីកាការពារ ដែលងាយស្រួលច្បាស់លាស់មិនស្មុគស្មាញសម្រាប់ស្ត្រីរងគ្រោះ។ ជម្រកសុវត្ថិភាព និងសេវាគាំទ្រជនរងគ្រោះ ចាំបាច់ត្រូវផ្តល់ជូនស្ត្រីរងគ្រោះ ហើយគោលនយោបាយ និងតួនាទីរបស់អាជ្ញាធរមូលដ្ឋានចាំបាច់ត្រូវត្រួតពិនិត្យឡើងវិញ។ នៅថ្នាក់មូល-ដ្ឋាន ការអប់រំសហគមន៍ពីសិទ្ធិ និងច្បាប់ទាក់ទងនឹងការសម្រុះសម្រួល នីតិវិធីនៃការលែងលះ និង បញ្ហាអំពើហិង្សាក្នុងគ្រួសារគឺមានសារៈសំខាន់ ហើយស្ត្រីត្រូវតែទទួលបានសេវាសម្រុះសម្រួលដោយឥតគិតថ្លៃ។រីឯបន្ទប់ ឬ ទីតាំងផ្តល់សេវា ត្រូវតែធានាអោយបានការរក្សាការសម្ងាត់ និងផ្តល់ភាពឯកជនដល់អ្នកទទួលសេវា។ ភាពជាអ្នកដឹកនាំស្មើភាពគ្នារបស់ស្ត្រី នៅក្នុងគណៈកម្មាការដោះស្រាយវិវាទ និងការអនុវត្តយន្តការនានាដែលឆ្លើយតបទៅនឹងអំពើហិង្សា គឺជាមូលដ្ឋានគ្រឹះសំខាន់ដែលមិនអាចខ្វះបាន។ក្រៅពីនេះគប្បីរឹតបន្តឹងនិងពិនិត្យឡើងវិញពីកាតព្វកិច្ចរបស់ប៉ូលីសក្នុងការរាយការណ៍អំពីបណ្តឹងព្រហ្មទណ្ឌ ទៅតាមតួនាទីរបស់ខ្លួន ព្រមទាំងពិនិត្យឡើងវិញនូវដែនកំណត់របស់ប៉ូលីសក្នុងការអនុវត្ត ADR។

សម្រាប់ព័ត៌មានបន្ថែមពីការសិក្សាស្រាវជ្រាវនេះ
សូមអានរបាយការណ៍ស្រាវជ្រាវពិស្តារ ដែលរួមមាន
វិធីសាស្ត្រស្រាវជ្រាវ ការត្រួតពិនិត្យឡើងវិញនូវ
ឯកសារសិក្សាធិការ និង ឯកសារគោលនយោបាយ
ការពិភាក្សានិងរបកគំហើញ និងអនុសាសន៍
ដោយចូលទៅកាន់គេហទំព័រ
wpmcambodia.org/project/ADRstudy

ឬ ទំនាក់ទំនងមក
wpm@women-peacemakers.org